THE CHURCH OF JESUS CHRIST OF LATTER-DAY SAINTS

Transforming Lives Through Nutrition

# អត្ថប្រយោជន៍ នៃគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ



## គ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ៖

- មានសារជាតិចិញ្ចឹមគ្រប់គ្រាន់ សម្រាប់ម្ដាយ និងទារក
- ផ្ដល់អាហារូបត្ថម្ភក្នុងអំឡុងពេលមានផ្ទៃពោះដើម្បីសុខភាពល្អ អនាគតបវររុងរឿង ។

## ហេតុអ្វីបានជា គ្រាប់ថ្នាំមីក្រូសារជាតិចម្រុះមានសារៈសំខាន់?

- គ្រាប់ថ្នាំមីក្រូសារជាតិចម្រុះសម្បូរទៅដោយវីតាមីនចម្រុះ និងរ៉ែខនិជចាំបាច់ជាច្រើន មានសារប្រយោជន៍ខ្លាំងដល់សុខភាពម្ដាយនិងទារក និងជួយបង្ការពីជំងឺជាច្រើនមុខក្នុងអំឡុងពេលមានផ្ទៃពោះ ព្រមទាំងជានានូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃការចាប់ផ្ដើមជីវិតរបស់ទារក និងកុមារ ។





## តើគ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ មានអត្ថប្រយោជន៍អ្វីខ្លះ?

- ការអភិវឌ្ឍទារកដែលមានសុខភាពល្អះជួយដល់ការលូតលាស់ខួរក្បាល ខួរឆ្អឹងខ្នង បេះដូង និងឆ្អឹង
- ការពារជំងឺពីកំណើតះកាត់បន្ថយគ្រោះថ្នាក់ពិការភាពរបស់បំពង់សរសៃប្រសាទ និងបញ្ហាផ្សេងៗទៀត
- ជួយប្រព័ន្ធភាពស៊ាំកាន់តែរឹងមាំខ្លាំងះជួយការពារអ្នក និងកូនរបស់អ្នកពីការឆ្លងមេរោគ
- កាត់បន្ថយហានិភ័យនៃផលវិបាកនៃការមានផ្ទៃពោះ៖ ជួយការពារភាពស្លេកស្លាំង កូនកើតមិនគ្រប់ខែ និងកូនកើតមិនគ្រប់គីឡូ ។

## តើធ្វើដូចម្ដេចដើម្បីទទួលបាន គ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ?

- ត្រូវពិភាក្សាជាមួយបុគ្គលិកសុខាភិបាលដើម្បីទទួលបាន គ្រាប់ថ្នាំមីក្រូសារជាតិចម្រុះ ។

